ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

# បច្ចេកទេសផលិតជីកំប៉ុស្ត
# និងថ្នាំកសិកម្មធម្មជាតិ



រៀបចំដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សហការជាមួយ
នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

ឧបត្ថម្ភការបោះពុម្ព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឆ្នាំ២០១៧



# សៀវភៅ

# ស្តីពី

# បច្ចេកទេសផលិតជីកំប៉ុស្ត

# និងថ្នាំកសិកម្មធម្មជាតិ

## រៀបចំដោយ


នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សហការជាមួយ
នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម



បោះពុម្ពលើកទី១ ចំនួន ២០០០ ច្បាប់

ឧបត្ថម្ភការបោះពុម្ពដោយ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



រក្សាសិទ្ធដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# សមាសភាពចូលរួមចំណែកផលិតសៀវភៅ
# ស្តីពីបច្ចេកទេសផលិតជីកំប៉ុស្តនិងថ្នាំកសិកម្មធម្មជាតិ

I. ទីប្រឹក្សាផ្តល់យោបល់:

| | | | |
|---|---|---|---|
| ១. បណ្ឌិត | **ហ៊ាន វណ្ណាហាន** | អគ្គនាយកដ្ឋានកសិកម្ម |
| ២. បណ្ឌិត | **ម៉ៅ មិនា** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៣. លោក | **ប៉ែន វុទ្ធី** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៤. លោក | **គឹម ដារ៉ា** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |

II. អ្នករៀបរៀង:

| | | |
|---|---|---|
| ១. លោក | **ផាន ទូច** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |

III. អ្នកស្រាវជ្រាវ:

| | | |
|---|---|---|
| ១. លោក | **វ៉ាត គឹមដាង** | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំ |

IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

| | | |
|---|---|---|
| ១. លោក | **ជួង អ៊ាង** | នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម |
| ២. លោក | **ទី ឈិន** | នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម |
| ៣. លោក | **ហុង ទ្រី** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៤. លោក | **ឈុន សុភ័ក្ត្រ** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |



## មាតិកា

ទំព័រ


១. សេចក្តីផ្តើម.............................................................................. ០១

២. ការផលិតជីកំប៉ុស្តគោក................................................................... ០២

  ២.១ វិធីសាស្ត្រនៃការផលិតជីកំប៉ុស្តគោក.............................................. ០២

៣. ការផលិតជីកំប៉ុស្តទឹក..................................................................... ១១

  ៣.១ វិធីសាស្ត្រនៃការផលិតជីកំប៉ុស្តទឹក................................................ ១១

  ៣.២ ការប្រើប្រាស់ជីកំប៉ុស្តទឹក............................................................. ១៣

៤. ការផលិតជីកំប៉ុស្តទ្រុង..................................................................... ១៤

  ៤.១ របៀបធ្វើទ្រុងជីកំប៉ុស្ត.................................................................. ១៤

៥. ការផលិតថ្នាំកសិកម្មធម្មជាតិ............................................................... ២១

  ៥.១ រុក្ខជាតិដែលអាចយកមកផ្សំជាថ្នាំកសិកម្មធម្មជាតិ.................................. ២១

  ៥.២ វិធីប្រើប្រាស់ថ្នាំកសិកម្មធម្មជាតិ........................................................ ២៥

## ១. សេចក្តីផ្តើម

ដីខ្សត់ជីជាតិ នៅតែជាកត្តាចម្បង នៅប្រទេសកម្ពុជានៅឡើយ ដែលជាហេតុនាំឱ្យទិន្នផលដំណាំ នៅមានកម្រិតទាប។ ការសឹករិចរិល នៃជីជាតិដីបណ្តាលមកពី៖

- ការហូរច្រោះនៃដី
- ការប្រើប្រាស់ជីធម្មជាតិនៅមានកម្រិតទាប
- ការប្រើប្រាស់ជីគីមីមិនត្រឹមត្រូវតាមបច្ចេកទេស
- ការដាំដំណាំដដែលៗតែមួយមុខ

នៅក្នុងធម្មជាតិ រុក្ខជាតិនានា និងពពួកសត្វទាំងឡាយដែលបានងាប់ហើយ រលួយដោយសារពពួកមីក្រូសារពាង្គកាយ (ផ្សិត បាក់តេរី វីរុស ។ល។) ដោយមានជំនួយពីទឹក ពន្លឺព្រះអាទិត្យ ខ្យល់ និងពេលវេលា ។ ដំណើរការពុកផុយនៃសារធាតុសរីរាង្គ (រុក្ខជាតិ និងពពួកសត្វ) បង្កើតបានជាសារធាតុចិញ្ចឹមរុក្ខជាតិ និងសារធាតុមមោក ដែលសម្បូរដោយជីជាតិ ដើម្បីផ្តល់ឱ្យដំណាំ និងរុក្ខជាតិនានា សម្រាប់ការដុះលូតលាស់ និងផ្តល់ផ្លែផ្កា។ ជីកំប៉ុស្តបានផ្តល់អត្ថប្រយោជន៍ជាច្រើនដូចជា៖

- ជួយកែលម្អជីជាតិ និងផលិតភាពដី
- ជួយឱ្យដីធូ ងាយស្រួលដល់ការលូតលាស់របស់ដំណាំ និងមានខ្យល់ចេញចូលបានល្អនៅក្នុងដី
- ជួយដីក្នុងការរក្សាទឹក និងជីជាតិ
- បង្កើនសកម្មភាព និងសត្វនៅក្នុងដី
- ជួយបង្កើនទិន្នផល និងគុណភាពផលិតផលដំណាំ
- ជួយជំរុញឱ្យការប្រើប្រាស់ជីគីមី មានប្រសិទ្ធភាពខ្ពស់ នៅពេលប្រើលាយជាមួយជីកំប៉ុស្ត
- បន្ថយជាតិពុលនៃដី

ក្រៅពីគុណប្រយោជន៍ផ្សេងៗគ្នាទាំងនេះ ការប្រើប្រាស់ជីកំប៉ុស្ត ជំនួសជីគីមី បានជួយកាត់បន្ថយការបំពុល និងការខូចខាតបរិស្ថាន និងជួយថែរក្សាប្រភពថាមពលដែលពុំអាចបង្កើតជាថ្មីឡើងវិញបាន។

## ២. ការផលិតជីកំប៉ុស្តគោក

### ២.១ វិធីសាស្ត្រនៃការផលិតជីកំប៉ុស្តគោក

- ពេលវេលានៃការផលិតជីកំប៉ុស្ត អាចធ្វើទៅបាននៅគ្រប់រដូវកាល។

**សម្ភារ**

ក. ឧបករណ៍ប្រើប្រាស់

រទេះគោសម្រាប់ដឹកជញ្ជូន រទេះរុញ លួស ចប ប៉ែល បង្គី កាំបិទ ពូថៅ ធុងទឹក បង្គោលឫស្សី បង្គោល ឈើ ខ្សែចំណង ។ល។













## ខ. វត្ថុធាតុសរីរាង្គ

ប្រមូលវត្ថុធាតុដើមមានដូចជាៈ ស្មៅស្រស់ ចំបើង ដើម និងស្លឹករុក្ខជាតិ ផេះ លាមកសត្វ និងកាកសំណល់ផ្សេងៗពីផ្ទះបាយ។



ស្មៅស្រស់



ដើមរុក្ខជាតិ



លាមកសត្វ



កាកសំណល់ពីក្រោលសត្វ



កាកសំណល់ផ្ទះបាយ



ស្លឹកឈើ



ចំបើង



វេះ ដីឥដ្ឋបូក និងអង្កាម

## ដំណើរការផលិតជីកំប៉ុស្តគោក

ការធ្វើជីកំប៉ុស្តមានច្រើនរបៀបដូចជាៈ របៀបធ្វើជីកំប៉ុស្តលើដីរៀបស្មើ របៀបធ្វើកំប៉ុស្តក្នុងរណ្តៅ និងរបៀបធ្វើជីកំប៉ុស្តទឹក។ល។

☞ ការផលិតជីកំប៉ុស្តលើដីរៀបស្មើ

**ជំហានទី១៖** ជ្រើសរើសទីតាំងដែលសមស្រប ជាទីទួល ឬកន្លែងមិនដក់ទឹក នៅជិតរោងចិញ្ចឹមសត្វ គួរជៀសវាងធ្វើពីខាងមុខ ឬជិតជាមួយនឹងផ្ទះពេក។

**ជំហានទី២៖** បោះបង្គោលឫស្សី ឬឈើដែលមានបណ្តោយ ៣ ម និង ទទឹង ២ ម ឬក៏អាចធំជាងនេះ។





ការរៀបចំដីធ្វើជីកំប៉ុស្ត

**ជំហានទី៣៖** ដើម្បីសាងសង់រោងជីត្រូវមាន កូនឈើ ឬដើមឫស្សី ស្លឹកត្នោត

ឬសង្កសី ខ្សែចាងត្នោត ដែកគោល ។ល។ ទំហំរោងត្រូវជីកដី បណ្តោយ៣ម ទទឹង ២ម៉ែត្រ ជម្រៅ ០,៥ ម ធ្វើជញ្ជាំងព័ទ្ធជុំវិញ ដែលមានកម្ពស់០,៥ ម ចាប់ពីមាត់រណ្តៅ ឡើងលើ និងប្រក់ដំបូលការពារកម្តៅថ្ងៃ និងទឹកភ្លៀង។




គំនូសបំព្រួញរោងជីកំប៉ុស្ត



រោងជីកំប៉ុស្ត

**ជំហានទី៤៖** ប្រមូលវត្ថុធាតុផ្សំធ្វើជីកំប៉ុស្ត មានស្លឹកឈើ ចំបើង អង្កាមដីដំបូក លាមកសត្វកាកសំណល់ផ្សេងៗ ពីផ្ទះបាយ មិនត្រូវដាក់វត្ថុរឹង មិនរលួយចូលក្នុង រណ្តៅឡើយដូចជា ថង់ប្លាស្ទីក អំបែងដប ដុំថ្ម កំណាត់ឈើ សម្លៀកបំពាក់។



ការជញ្ជាំដើមទន្ទ្រានខេត្ត



ការដាក់វត្ថុធាតុផ្សំនៅបាតរណ្តៅ

**ជំហានទី៥៖** ក្រាលស្រទាប់ស្មៅ ស្លឹកឈើ ចំបើង និងរុក្ខជាតិផ្សេងៗទៅលើដី ស្រទាប់នេះអាចមានកម្រាស់ ៧-១៥ ស.ម និងត្រូវមានសំណើមជានិច្ច តែមិនត្រូវជោគ ជាំពេកទេ។






*ការក្រាលស្រទាប់ស្មៅ ឬវត្ថុធាតុផ្សេងៗ*

**ជំហានទី៦៖** នៅពីលើស្រទាប់ទី១នេះ ត្រូវក្រាលផេះ និងលាមលសត្វពីលើ និងកាយ ឬច្របល់ឱ្យបានសព្វល្អ។ ស្រទាប់នេះមានកម្រាស់ប្រហែលជា១៥-៣០ ស.ម ។ អាចដាក់ជីកំប៉ុស្តចាស់តិចទួចបន្ថែមទៀតពីព្រោះជាប្រភពដ៏ល្អនៃអតិសុខុមប្រាណដែលជួយបំបែកនូវសារធាតុសរីរាង្គទាំងនោះ។ មិនត្រូវសង្កត់ស្រទាប់នោះឱ្យហាប់ណែនឡើយប្រសិនបើគំនរជីកំប៉ុស្តនោះហាប់ណែនពេក ការរលួយមានភាពយឺតយ៉ាវ។





*ការដាក់ផេះនិងជីលាមកសត្វកម្រាស់៣០ ស.ម នៅស្រទាប់ទី២*

**ជំហានទី៧៖** បន្ថែមស្រទាប់ដីពីលើប្រហែល ២-៣ ស.ម ដើម្បីបន្តស្រទាប់ថ្មីបន្តទៀត ។ ត្រូវប្រាកដថាគ្មានដុំគ្រោះ ដុំថ្ម ដុំដីធំៗនិងដង្គុំឈើឡើយ។ ដីផ្ទុកនូវអតិសុខុមប្រាណ និងជួយពន្លឿនការបំបែកសារធាតុឱ្យរលួយបានឆាប់រហ័ស ព្រោះថាការងារនេះជាមូលដ្ឋានគ្រឹះសម្រាប់គំនរជី។